ព្រឹត្តិបត្រផ្សព្វផ្សាយកសិកម្ម AGRICULTURAL EXTENSION BULLETIN

ឆ្នាំទី ០១ លេខ ០៧ ខែកក្កដា ឆ្នាំ ២០១៥ ចេញផ្សាយដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម A PUBLICATION OF THE DEPARTMENT OF AGRICULTURAL EXTENSION



# បទពិសោធន៍ជោគជ័យកសិករជ័យលាភី យន ម៉ៅ លើការចិញ្ចឹមត្រី និងផលិតកូនត្រីពូជ

លោក **យន ម៉ៅ** ជាកសិករផលិតកូនត្រីពូជ នៅស្រុកមេសាង ខេត្តព្រៃវែង ប្រភេទត្រី ដែលគាត់ចិញ្ចឹម និងផលិតគឺជាប្រភេទត្រីឆ្ពិន កាបសាមញ្ញ កាបឥណ្ឌា កាបស និងត្រីទីឡាព្យា។

**ជំហាននៃការចិញ្ចឹមត្រី:**

**១. ការរៀបចំស្រះមុនពេលដាក់ត្រីចិញ្ចឹម**

- បូមទឹកពង្រីងស្រះ
- សម្អាតស្មៅលើភ្លឺស្រះ
- ស្តារភក់បាតស្រះ ១០-១៥ សម
- បាចកំបោស ៥-៧ គ.ក្រ/១០០ ម² ស្រះ
- ហាលថ្ងៃ ២-៣ ថ្ងៃ
- បញ្ចូលទឹកចូលស្រះដំបូងជម្រៅ ៣០ ស.ម
- ដាក់ជីលាមកគោ ៥០-៨០ គ.ក្រ/១០០ ម² ក្នុងស្រះ
- ស្លឹកទន្រ្ទាងខេត្រ ៣-៤ បាច់ /១០០ ម² ស្រះ
- បញ្ចូលទឹកបង្គ្រប់ជម្រៅ ១-១.៥ម រហូតដល់ទឹកមានពណ៌បៃតងទើបអាចលែងកូនត្រីចូលស្រះចិញ្ចឹមបាន ។

**២. របៀបលែងកូនត្រីចូលស្រះក្រោយពេលដឹកជញ្ជូន**

- ត្រាំថង់កូនត្រីក្នុងស្រះរយៈពេលពី១០-២០ នាទីមុនពេលលែងកូនត្រីចូលស្រះចិញ្ចឹម

- លែងកូនត្រីចេញពីថង់ចូលស្រះដោយសន្សឹមៗ នូវកម្រិតដង់ស៊ីតេ ១-៤ ក្បាល/ម²ស្រះ

១. ត្រាំថង់ក្នុងស្រះ

៣. លែងកូនត្រីចូលស្រះ



២. បើកមាត់ថង់



### ៣. ការដឹកជញ្ជូន

- បង្អឹកកូនត្រីមុនដឹកជញ្ជូន ១ថ្ងៃ
- វិចខ្ចប់កូនត្រី
- រៀបចំដឹកជញ្ជូន








### ៤. ការចិញ្ចឹមតាមបែបលក្ខណៈចម្រុះ

សមាសភាពត្រីដាក់ចិញ្ចឹម:

- ឆ្ពិន ៤០%
- ទីឡាព្យា ៣០%
- កាបស ២០%
- កាបសាមញ្ញ/ឥណ្ឌា ១០%



### ៥. ការគ្រប់គ្រងស្រះក្រោយពេលដាក់ត្រីចិញ្ចឹម

- បិទរន្ធក្ដាម កង្កែប នៅតាមមាត់ស្រះ
- ផ្ដល់ចំណីបន្ថែមឱ្យបានទៀងទាត់
- បង្ហូរទឹកជីចូលក្នុងស្រះ
- បញ្ឈប់ បង្ហូរទឹកជីចូលក្នុងស្រះ
- កាកសំណល់ជីត្រូវផ្លាស់ប្ដូរថ្មីនូវរៀងរាល់២០-៣០ថ្ងៃម្ដង។




- ដើមទន្រ្ទាំងខែត្រ ២បាច់
- លាមកគោ៥០-៨០គ.ក្រ
- បញ្ចូលទឹកឱ្យពេញរណ្ដៅ



# ការផលិតកូនត្រីពូជ





## ១. ការគ្រប់គ្រងត្រីមេពូជ

- ប្រភពត្រីមេពូជ ជ្រើសរើសមកពីតំបន់ផ្សេងៗគ្នា
- អាយុត្រីមេពូជ ១ឆ្នាំ ឡើងទៅ
- ទម្ងន់ត្រីមេពូជ ( ឆ្ពិន ២៥០-៥០០ក្រាម កាបស ៧០០ -១៥០០ក្រាម កាបសាមញ្ញ ៥០០ក្រាម កាបឥណ្ឌា ៤០០-១៥០០ក្រាម ទីឡាព្យា ១៥០-៣០០ក្រាម )។
- ស្រះបំប៉នត្រីមេពូជ ២០០ម$^{២}$ ឡើងទៅ
- រយៈពេលបំប៉នត្រីមេពូជ ខែតុលា ដល់ ខែកុម្ភៈ
- ដង់ស៊ីតេត្រីដាក់បំប៉ន ១-២ក្បាល /ម$^{២}$ស្រះ
- បរិមាណចំណី ៣% ធៀបទម្ងន់ដងខ្លួន ( ផ្តល់ឱ្យត្រីស៊ី ២ដង/ថ្ងៃ )
- សមាសធាតុចំណីបំប៉នត្រីមេពូជ រួមមានកន្ទក់ម៉ដ្ឋ ចុងអង្ករ សណ្តែកសៀង ម្សៅត្រី កាកសំណល់បន្លែ និងចំណីគ្រាប់។

## ២. ការប្រើប្រាស់អ័រម៉ូន

| | ប្រភេទត្រី | ញី<br>( មីលីលីត្រ/គ.ក្រត្រី ) | ឈ្មោល<br>( មីលីលីត្រ/គ.ក្រ ត្រី ) |
|---|---|---|---|
| ឆ្ពិន |  | 0.១-0.៣ | 0-0.0៥ |
| កាបសាមញ្ញ |  | 0.១-0.៣ | 0-0.0៥ |
| កាបស |  | 0.៣-0.៥ | 0.១៥-0.២៥ |
| កាបឥណ្ឌា |  | 0.៣-0.៥ | 0.១៥-0.២៥ |
| ទីឡាព្យា |  | 0 | 0 |






ត្រីកាបស កាបសាមញ្ញ កាបឥណ្ឌា ( អាចចិញ្ចឹមជាមួយគ្នាបានប្រសើរ )

## ៣. ប្រព័ន្ធអាងបង្កាត់ ភ្ញាស់ត្រី







## ៤. ការរៀបចំស្រះបំប៉នកូនត្រី

- ទំហំស្រះ ២០០ម$^{២}$
- ជម្រៅស្រះ ០,៥ ម
- បូមទឹកពង្រីងស្រះ
- បាចកំបោរសពី ៥-៧ គ.ក្រ/១០០ម$^{២}$
- ហាលស្រះ ២-៣ថ្ងៃ
- បញ្ចូលទឹកចូលស្រះដំណាក់កាលដំបូង ៣០ស.ម
- ដាក់លាមកគោ៥០-៨០គ.ក្រ/១០០ម$^{២}$ ឬ លាមកមាន់ ១០-១៥ គ.ក្រ/១០០ម$^{២}$
- បញ្ចូលទឹកចូលស្រះបង្គ្រប់ ១០០% ក្នុងរយៈពេល ៣-៤ថ្ងៃ រួចលែងកូនត្រីចូលស្រះបំប៉ន
- បង្ហូរទឹកចូលស្រះដោយមានតម្រងច្រោះ ។



## ៥. ការផ្តល់ចំណីកូនត្រីពូជ

- ចំណីចំនួន១គ.ក្រសម្រាប់កូនត្រី ៥០០០០០ ក្បាល ក្នុងនោះ ៖
- សណ្តែកសៀង ០,៣ គ.ក្រ
- កន្ទក់ម៉ដ្ឋចំនួន ០,៥ គ.ក្រ
- ម្សៅត្រីចំនួន ០,១ គ.ក្រ និង
- ប្រហុកចំនួន ០,១ គ.ក្រ
- ផ្តល់ឱ្យកូនត្រីស៊ីពី ៣-៤ដងក្នុងមួយថ្ងៃ
- ឧស្សាហ៍ប្តូរទឹកថ្មីចូលក្នុងស្រះបំប៉ន ចំនួន ១/៣ នូវរៀងរាល់ពីរសប្តាហ៍ម្តង៕




**សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមក៖**

- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម
  តាមអាសយដ្ឋាន ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ
  ទូរស័ព្ទលេខ : (០២៣) ២១៥ ៨១៩/០១២ ៨៣ ៧៩ ៤៥
  ទូរសារលេខ : (៨៥៥)២៣ ២១០ ៩៤៨
  Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម / Department of Agricultural Extension
  គេហទំព័រ : http://www.maff.gov.kh
  អ៊ីម៉ែល : info@maff.gov.kh
- លោក **យន ម៉ៅ** កសិករជ័យលាភី លើការចិញ្ចឹម និងផលិតកូនត្រីពូជ
  តាមអាសយដ្ឋាន ភូមិច្រេស ឃុំច្រេះ ស្រុកមេសាង ខេត្តព្រៃវែង